# ការលើកកម្ពស់ការបំពេញការងារ គណនេយ្យភាព និងការចូលរួមរបស់ប្រជាពលរដ្ឋ (SPACE) ដោយក្រុមប្រឹក្សាតាមបែបប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា

ទិដ្ឋភាពទូទៅ

កម្មវិធី EU SPACE សម្រាប់លើកកម្ពស់ការបំពេញការងារ គណនេយ្យភាព និងការចូលរួមរបស់ប្រជាពលរដ្ឋដោយក្រុមប្រឹក្សាតាមបែបប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា ផ្តល់ការគាំទ្រដល់ការអនុវត្តកម្មវិធីជាតិ ១០ ឆ្នាំ ស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០១០-២០១៩ (NP-SNDD)។

កម្មវិធីជាតិស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ មានគោលបំណងលើកកម្ពស់ស្ថាប័នប្រជាធិបតេយ្យនៅមូលដ្ឋាន និងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ កម្មវិធីនេះមានគោលបំណងបង្កើតនូវប្រព័ន្ធ និងសមត្ថភាព ដែលនាំឱ្យ (i) ក្រុមប្រឹក្សាមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ និងអាចរៀបចំបង្កើតគោលនយោបាយអភិវឌ្ឍន៍នៅក្នុងមូលដ្ឋានរបស់ខ្លួនបាន និង (ii) រចនាសម្ព័ន្ធប្រតិបត្តិ និងរដ្ឋបាល ដែលមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា និងអាចអនុវត្តគោលនយោបាយទាំងនេះបានប្រកបដោយប្រសិទ្ធភាព។ ទាំងច្បាប់ស្តីពីការរៀបចំអង្គការឆ្នាំ ២០០៨ និង កម្មវិធីជាតិស្តីអំពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឆ្នាំ ២០១០ បានបញ្ជាក់ថា ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ គឺជាស្ថាប័នតំណាងកម្រិតនយោបាយ ដែលទទួលខុសត្រូវលើការបង្កើត លើកកម្ពស់ និងធានានិរន្តរភាព ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ តាមរយៈការធ្វើឱ្យមានការផ្លាស់ប្តូរលក្ខណៈនៃគណនេយ្យភាព នៅក្នុងរដ្ឋឯកភាព ការផ្លាស់ពីការគ្រប់គ្រងតាមបែបមជ្ឈការការិយាធិបតេយ្យ ទៅជារដ្ឋបាលថ្នាក់ក្រោមជាតិដែលមានស្វ័យភាព និងមានគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ។ គណនេយ្យភាព តាមបែបប្រជាធិបតេយ្យ គឺជាស្នូលនៃការរៀបចំបែបនេះ។

យោងតាមអនុស្សារណៈអំពីកម្មវិធី SPACE ខែ មីនា ឆ្នាំ ២០១០ និងដោយមានការអនុលោមទៅតាមក្រមប្រតិបត្តិរបស់សហភាពអឺរ៉ុបស្តីពីភាពបំពេញបន្ថែមឱ្យគ្នា និងការបែងចែកការងារនៅក្នុងគោលនយោបាយស្តីពីការអភិវឌ្ឍ សមាជិករបស់សហភាពអឺរ៉ុបចំនួន ០៣ប្រទេស និងប្រតិភូសហភាពអឺរ៉ុប បានរួមគ្នាបង្កើតនូវយន្តការតែមួយ ដើម្បីផ្តល់ការគាំទ្ររបស់ពួកគេដល់

ការលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលជាការរួមចំណែកចំពោះការអនុវត្តកម្មវិធីជាតិស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ កម្មវិធី EU SPACE គឺជាសមិទ្ធផលមួយនៃការលើកកម្ពស់ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ និងជាលទ្ធផលរូបីយដំបូងគេបង្អស់នៃការបែងចែកការងាររបស់សហភាពអឺរ៉ុប ដែលចាប់ផ្តើមមាននៅក្នុងប្រទេសកម្ពុជានៅក្នុងឆ្នាំ ២០០៨ បន្ទាប់ពីមានផែនការសកម្មភាពទីក្រុងអាក្រា រួចមក។

កម្មវិធី EU SPACE ដែលជាកម្មវិធីរួមគ្នានេះ ត្រូវបានរៀបចំឡើង ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមសំខាន់ៗចំនួន ៣ នៅក្នុងកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលបញ្ហាប្រឈមទាំងនេះនាំឱ្យមានការចុះខ្សោយនូវសម្លេងរបស់ប្រជាពលរដ្ឋ និងគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ។ បញ្ហាប្រឈមទាំងនោះរួមមាន ៖

- ការធ្វើការងារដោយឡែកពីគ្នារបស់ដៃគូអភិវឌ្ឍន៍
- គម្លាតនៅក្នុងកម្មវិធីជាតិស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងការផ្តោតការយកចិត្តទុកដាក់នៅមានកម្រិតនៃជំនួយបច្ចេកទេសប្រតិបត្តិការលើការផ្តល់សេវា/បញ្ហា ដែលពាក់ព័ន្ធជាមួយនឹងប្រតិបត្តិការជាក់ស្តែង និង
- ឱកាសពិគ្រោះយោបល់របស់ប្រព័ន្ធ និងរចនាសម្ព័ន្ធនានា នៅមានកម្រិត

គោលដៅជារួមរបស់កម្មវិធី EU SPACE គឺដើម្បីគាំទ្រដល់ស្ថាប័នជាតិ និងក្រោមជាតិ នៅក្នុងការរួមគ្នាបង្កើតរចនាសម្ព័ន្ធ នីតិវិធី និងសមត្ថភាពនានា ដើម្បីឱ្យស្ថាប័នទាំងនេះកាន់តែអាចឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។ នេះមានន័យថា ជាការពង្រឹងឱកាសពិគ្រោះយោបល់ (ឬនយោបាយ) ដែលតាមរយៈឱកាសនេះ តំណាងដែលត្រូវបានជ្រើសតាំងតាមរយៈការបោះឆ្នោត អាចធ្វើសេចក្តីសម្រេចចិត្តប្រកបដោយអត្ថន័យ និងត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ នូវរាល់សេចក្តីសម្រេចទាំងនោះ។ កម្មវិធីនេះត្រូវបានរំពឹងថានឹងលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋទូទៅ តាមរយៈការចូលរួមចំណែកសម្រេចគោលដៅរបស់ប្រជាពលរដ្ឋ និងរបស់រដ្ឋ ដើម្បីចូលរួមនៅកិច្ចពិគ្រោះយោបល់ប្រកបដោយលក្ខណៈស្ថាបនា និងប្រកបដោយការចូលរួមអំពីជម្រើសនៃការអភិវឌ្ឍ សិទ្ធិ និង សេវា និងការបង្កើនការយល់ដឹងអំពីការធ្វើខ្លួនជាប្រជាពលរដ្ឋល្អរបស់ប្រជាពលរដ្ឋ។

ដើម្បីសម្រេចគោលដៅរួមនេះ កម្មវិធី EU SPACE អនុវត្តការងារ ដោយផ្តោតលើលទ្ធផលចំនួន ៥ ដូចខាងក្រោម ៖

១. កិច្ចពិគ្រោះយោបល់រវាងសហភាពអឺរ៉ុប និងរាជរដ្ឋាភិបាលកម្ពុជា និងបេសកកម្ម ៖ ការគាំទ្រដល់ការរៀបចំអភិក្រមកម្មវិធីពហុអ្នកផ្ដល់ជំនួយ ដើម្បីអនុវត្តកម្មវិធីជាតិស្ដីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

២. អភិក្រមដើម្បីសម្រេចនូវគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ៖ ការផ្ដល់ដំបូន្មានគោលនយោបាយអំពីការពង្រឹង សម្លេង និងការត្រួតពិនិត្យ

៣. គំរូសម្រាប់ការចូលរួមរបស់ប្រជាពលរដ្ឋ ៖ ការពង្រឹងក្រុមប្រឹក្សា ដើម្បីឱ្យមានការចូលរួមពីប្រជាពលរដ្ឋ នៅតាមតំបន់គោលដៅ (ខេត្តចំនួន ២) សំដៅគាំទ្រដល់សម្លេងរបស់ប្រជាពលរដ្ឋ និងការត្រួតពិនិត្យ

៤. ការយល់ដឹង ៖ ពង្រឹងការចូលរួមរបស់សង្គមស៊ីវិល

៥. ពង្រឹងភាពឆ្លើយតប ៖ ការប្រគល់មុខងារដល់ថ្នាក់ក្រោមជាតិ។

ការផ្ដោតសំខាន់នៃអភិក្រមការងាររួមគ្នារបស់សហភាពអឺរ៉ុប គឺការបង្កើតនូវប្រព័ន្ធគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ តាមរយៈក្រុមប្រឹក្សា ដែលត្រូវបានជ្រើសតាំងតាមរយៈការបោះឆ្នោត។ ការអនុវត្តកម្មវិធី EU SPACE នេះ បានសម្រេចនូវលទ្ធផលគួរឱ្យកត់សម្គាល់ជាពិសេស ពាក់ព័ន្ធជាមួយនឹងការដាក់បញ្ចូលវិមជ្ឈការតាមបែបប្រជាធិបតេយ្យ ទៅក្នុងផែនការដើម្បីអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ៣ ឆ្នាំដំបូង (ផអ៣) ដោយមានការចែងយ៉ាងច្បាស់ថា ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិត្រូវមានគណនេយ្យភាពតាមបែបប្រជាធិបតេយ្យចំពោះប្រជាពលរដ្ឋ ហើយរដ្ឋបាលថ្នាក់ក្រោមត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា ដែលត្រូវបានជ្រើសតាំងតាមរយៈការបោះឆ្នោត។